**Cambodian - Urticaria (Hives)**

ជម្ងឺរលាកស្បែក



# កន្ទាលត្រអាក

## ចំណុចសំខាន់ៗ

- ករណីភាគច្រើននៃកន្ទាលត្រអាកឥតមានប្រភពជាក់លាក់ឡើយ
- ហេតុផលទូទៅភាគច្រើនដែលត្រូវបានគេយល់ឃើញថាបណ្តាលឲ្យកើតកន្ទាលត្រអាក នោះគឺជាមេរោគ
- កន្ទាលត្រអាកអាចបណ្តាលមកពីការទាស់ទៅនឹងម្ហូបអាហារខ្លះៗ
- ជៀសវាងកំដៅនៅពេលកើតកន្ទាលត្រអាក ហើយខិតខំធ្វើឲ្យត្រជាក់ស្បែកតាមដែលអាចធ្វើទៅបាន
- ថ្នាំទឹកស៊ីរ៉ូម antihistamine (ថ្នាំទឹកស៊ីរ៉ូមប្រឆាំងប្រតិកម្មជាតិពុល) ដែលចេញដោយវេជ្ជបណ្ឌិត នឹងជួយទប់ទល់ការធ្វើទុក្ខខ្លាំងបំផុតនៃកន្ទាលត្រអាក ប្រសិនបើឲ្យផឹកភ្លាមៗ
- ទឹកថ្នាំលាងស្បែក និងក្រែម សំរាប់លាបនៅលើស្បែក មិនសូវធ្វើឲ្យស្បែកជាគ្រាន់បើប៉ុន្មានទេ

## តើវាជាអ្វី?

កន្ទាលត្រអាកតែងកើតមានទូទៅនៅក្នុងចំណោមកុមារ។ វាលេចឲ្យឃើញដូចជាស្នាមកន្ទួលក្រហម ដែលកើតភ្លាមៗក្នុងរយ:ពេលប៉ុន្មាននាទី ស្ថិតនៅអស់រយ:ពេលប្រហែលជាមួយម៉ោង រួចមកក៏ជាបាត់អស់ទៅវិញរលីង ហើយស្បែកក៏ត្រឡប់ទៅជាធម្មតាវិញ។ ជួនកាលនៅក្នុងចំណោមកុមារ កន្ទាលត្រអាកមានអាការ:ដូចជាស្នាមជាំ។ កាលណាកុមារកើតមានកន្ទាលត្រអាកហើយនោះ កំដៅនឹងធ្វើឲ្យទៅជាធ្ងន់ធ្ងរ ឬកាន់តែរមាស់ឡើង។

## តើវាកើតនៅកន្លែងណា?

វាអាចកើតមាននៅគ្រប់កន្លែងលើខ្លួនប្រាណដូចជាមុខ ដងខ្លួន និងដៃជើង។ ការធ្វើទុក្ខភាគច្រើនកើតមានអស់រយ:ពេលពីរ ទៅបីថ្ងៃប៉ុណ្ណោះដែលនៅពេលនោះស្នាមកន្ទួលក៏កើតមាន ហើយជាបាត់ទៅវិញ។ ជួនកាលកន្ទាលត្រអាកអាចចេះតែលេចឲ្យឃើញ ហើយជាបាត់ទៅវិញអស់រយ:ពេលរាប់ខែ។

## តើវាបណ្តាលមកពីអ្វី?

នៅក្នុងករណីនៃកន្ទាលត្រអាកភាគច្រើន ឥតមានប្រភពជាក់លាក់ឡើយ។ នេះត្រូវបានគេយល់ឃើញថា មេរោគប្រហែលជាមូលហេតុទូទៅភាគច្រើន ដែលបណ្តាលឲ្យកើតកន្ទាលត្រអាកនៅក្នុងចំណោមកុមារ។ ក៏ប៉ុន្តែជាញឹកញយក្រៅពីការកើតកន្ទាលត្រអាកនោះ កុមារមានសុខភាពល្អទេ។ នៅក្នុងករណីនេះ កន្ទាលត្រអាកហាក់បីដូចជាធូរស្បើយឡើងវិញក្នុងរយ:ពេលតិចជាងមួយអាទិត្យ ហើយវាអាចកើតឡើងវិញម្តងទៀតជាមួយជម្ងឺឯទៀត។ មេរោគបាក់តេរីក៏អាចបណ្តាលឲ្យកើតកន្ទាលត្រអាកផងដែរ ហើយអាចត្រូវការថ្នាំអង់ទីប៊ីយោទិក។ កន្ទាលត្រអាកក៏អាចបណ្តាលមកពីការទាស់ផងដែរទៅនឹងអ្វីដែលកុមារបានញ៉ាំ ដូចជាផ្លែស្ត្របឺរី ឬម្ហូបសមុទ្រ។ ជួនកាលថ្នាំពេទ្យដូចជាថ្នាំ penicillin (ប៉េនីស៊ីលីន) អាចបណ្តាលឲ្យកើតកន្ទាលត្រអាក។

## តើគេព្យាបាលវាដោយរបៀបណា?

ស្នាមរមាស់កន្ទួលក្រហមនៅស្បែក បណ្តាលមកពីការបញ្ចេញនូវ histamine (ហ៊ីស្តាមីន) ដែលជាការឆ្លើយតបកើតមាននៅក្នុងស្បែកបណ្តាលមកពីប្រតិកម្ម។ ហេតុដូច្នេះគេតែងព្យាបាលវាជាមួយថ្នាំទឹកស៊ីរ៉ូម antihistamine ដែលតាមធម្មតាចេញដោយវេជ្ជបណ្ឌិត។ ថ្នាំនេះនឹងទប់ទល់ការធ្វើទុក្ខភាគច្រើននៃកន្ទាលត្រអាក។ ត្រូវជៀសវាងកំដៅនៅពេលកើតកន្ទាលត្រអាក ដោយហេតុថាវានាំឲ្យធ្ងន់ធ្ងរឡើង។ ការដាក់កុមារឲ្យត្រជាក់ស្រួលជាមួយកង្ហាល់ ឬការដាក់ក្រណាត់សើមនៅលើកន្លែងរមាស់ នឹងជួយកាត់បន្ថយរមាស់ ហើយពង្រួញរយ:ពេលធ្វើទុក្ខឲ្យនៅខ្លី។ ទឹកថ្នាំលាងស្បែក និងក្រែមសំរាប់លាបនៅលើស្បែក មិនសូវធ្វើឲ្យស្បែកជាគ្រាន់បើប៉ុន្មានទេ។

ការធ្វើទុក្ខភាគច្រើននៃកន្ទាលត្រអាក ទាក់ទិននឹងចំណីអាហារដែលកើតឡើងក្នុងរយ:ពេល១២ម៉ោងនៃការញ៉ាំ។ ត្រូវខិតខំរកឲ្យឃើញចំណីអាហារណាមួយដែលកូនរបស់លោកអ្នកបានញ៉ាំក្នុងរយ:ពេល១២ម៉ោង មុនកើតកន្ទាលត្រអាកមួយលើកៗ។ លោកអ្នកប្រហែលជាអាចនឹងរកឃើញចំណីអាហារណាមួយដែលបណ្តាលឲ្យធ្វើទុក្ខ ហើយត្រូវជៀសវាងញ៉ាំវានៅពេលក្រោយ។

**Cambodian - Urticaria (Hives)**

## ពត៌មានបន្ថែមទៀត

- វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក
- គិលានុបដ្ឋាយិកាមើលថែទាំសុខភាពមាតា និងកុមារ
- ឱសថការីរបស់លោកអ្នក
- វេជ្ជបណ្ឌិតឯកទេសជម្ងឺសើរស្បែក ឬអ្នកឯកទេសខាងការទាស់កន្ទាលត្រអាកដែលកើតមានឥតដាច់

© 2002, Department of Dermatology, St. Vincent’s Hospital Melbourne, Victoria Parade, Fitzroy, Victoria 3065 Australia.